ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ៦

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



# Work Activities

ប្រចាំខែមិថុនា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីគ្រប់គ្រងដីចំណីផ្លូវតាមបណ្តាញផ្លូវជនបទ នៃព្រះរាជាណាចក្រកម្ពុជា | ១ |
| ២- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែឧសភា ឆ្នាំ២០១៣ | ៣ |
| ៣- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# គ្រប់គ្រងដីចំណីផ្លូវតាមបណ្តាញផ្លូវជនបទ នៃព្រះរាជាណាចក្រកម្ពុជា

កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទីនិងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុខ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីគ្រប់គ្រងដីចំណីផ្លូវតាមបណ្តាញផ្លូវជនបទនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអភិវឌ្ឍន៍ជនបទ។



ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីគ្រប់គ្រងដីចំណីផ្លូវតាមបណ្តាញផ្លូវជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងលុបបំបាត់រាល់បាតុភាពទន្ទ្រានកាន់កាប់ដីចំណីផ្លូវដោយខុសច្បាប់ បញ្ចៀសបាននូវរាល់ឧបទ្ទវហេតុដែលអាចបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍ រក្សាសណ្តាប់ធ្នាប់សង្គម បរិស្ថានបានល្អ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ដំណើរការអភិវឌ្ឍបណ្តាញផ្លូវជនបទ ដែលអាចឆ្លើយតបបានយ៉ាងពិតប្រាកដទៅនឹងសំណូមពរនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ដើម្បីចូលរួមចំណែកការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ លើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋ និងបង្កើនសក្តានុពលបន្ថែមទៀតដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ និងភាពស្របច្បាប់លើដីធ្លីដែលស្ថិតនៅតាមបណ្តាញផ្លូវជនបទព្រមទាំងបានរួមចំណែកក្នុងការសន្សំសំចៃថវិការដ្ឋ លើការចំណាយសំណងដែលពាក់ព័ន្ធនឹងផលប៉ះពាល់នៅពេលធ្វើការសាងសង់ ឬកែលម្អផ្លូវជនបទ។

សេចក្តីព្រាងអនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ទៅលើផ្លូវជនបទទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងអភិវឌ្ឍន៍ជនបទ លើកលែងផ្លូវជនបទដែលស្ថិតនៅក្នុងដែនបម្រុងសត្វព្រៃ និងឧទ្យានជាតិ និងក្នុងដែនបម្រុងរុក្ខា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង

បរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីព្រាងអនុក្រឹត្យផ្តោតលើខ្លឹមសារសំខាន់ៗ សំដៅធានាបាននូវប្រសិទ្ធភាពនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទជាពិសេសបណ្តាញផ្លូវជនបទ និងធានាបាននូវការប្រើប្រាស់ផ្លូវប្រកបដោយចីរភាព។ ដើម្បីសម្រេចបានគោលដៅរបស់សេចក្តីព្រាងអនុក្រឹត្យនេះ ទំហំដីចំណីផ្លូវទៅតាមប្រភេទផ្លូវជនបទ និងអំពីសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ដីចំណីផ្លូវត្រូវបានកំណត់ សម្រាប់ជាផលប្រយោជន៍សាធារណៈ និងឯកជន(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីពាងអនុក្រឹត្យនេះ ដោយសមាជិកអង្គប្រជុំខ្លះបានលើកឡើងថា គួររង់ចាំសេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់ចេញសិន ទើបលើកយកសេចក្តីព្រាងអនុក្រឹត្យនេះមកពិចារណា ក៏ប៉ុន្តែសាមីក្រសួង និងសមាជិកអង្គប្រជុំផ្សេងទៀតបានលើកឡើងថា បើយើងរង់ចាំច្បាប់ស្តីពីផ្លូវថ្នល់ចេញនោះវាយូរពេក នាំឲ្យមានការលំបាកក្នុងការគ្រប់គ្រងចំណីផ្លូវជនបទ ក្រសួងអាចបង្កើតបទប្បញ្ញត្តិដោយឡែក និងអន្តរប្បញ្ញត្តិ ដោយធ្វើយ៉ាងណាកុំឲ្យវាផ្ទុយនឹងច្បាប់ស្តីពីផ្លូវថ្នល់។ អង្គប្រជុំបានសម្រេចបន្តពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងអនុក្រឹត្យនេះ ដោយកត់ត្រាទុកនូវអ្វីដែលសមាជិកអង្គប្រជុំខ្លះបានលើកឡើងថា គួររង់ចាំសេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់ចេញសិន ហើយនឹងលើកបញ្ហានេះនៅក្នុងអង្គប្រជុំអន្តរក្រសួងនាពេលខាងមុខ។ អង្គប្រជុំបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីគ្រប់គ្រងដីចំណីផ្លូវតាមបណ្តាញផ្លូវជនបទនៃព្រះរាជាណាចក្រកម្ពុជា។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា
# ប្រចាំខែឧសភា ឆ្នាំ២០១៣



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែឧសភា ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែឧសភា ឆ្នាំ២០១៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,៧% ធៀបនឹងខែមុន និងកើនឡើង ២,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន(រយៈពេល១២ខែ)។ ការកើនឡើងថ្លៃទំនិញប្រើប្រាស់ធៀបនឹងខែមុននេះជាចម្បងបណ្តាលមកពីក្រុមម្ហូបអាហារ ដែលមានការរួមចំណែក ៦៩% ទៅលើការឡើងថ្លៃសរុប។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុនក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | | |
|---|---|---|
| *ក្រុមទំនិញ៖* | *មុខទំនិញ៖* | |
| ម្ហូបអាហារ: +៤,១%<br>សម្លៀកបំពាក់និងស្បែកជើង : +៤,៧%<br>គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ : +៣,៥%<br>សុខាភិបាល: +១,៩%<br>ការដឹកជញ្ជូន: -១,០%<br>ភោជនីយដ្ឋាន: +៦,០% | អង្ករ: +៣,៥%<br>សាច់គោស្រស់: +១៣%<br>សាច់មាន់ស្រស់: +៤,៤%<br>ត្រីស្រស់: : +៤,១%<br>បន្លែ: +៦,៩% | ឧស្ម័ន: -៨,៤%<br>ប្រេងសាំង: -0,១%<br>ប្រេងម៉ាស៊ូត: +១,៩% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀស តាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១១-២០១៣

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា^P | កក្កដា^P | សីហា^P | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៧% | ៣,០% | ៣,១% | | | | | - |
| | ខែមុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០% | ០,៣% | ១,២% | | | | | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | ខែមុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ១,១% | ០,២% | -០,២% | -០,២% | ០ | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |

P: តួលេខខែ មិថុនា កក្កដា **និងសីហា** ឆ្នាំ២០១៣ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្រ្ត **DECOMPOSITION**)

ក្រាហ្វ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ២០១១ ២០១២ និង ២០១៣ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




➡អត្រាប្តូរប្រាក់៖

| ប្រភេទ | ឧសភា ២០១៣ | មេសា ២០១៣ | ឧសភា ២០១២ | ប្រភេទ | ឧសភា ២០១៣ | មេសា ២០១៣ | ឧសភា ២០១២ |
|---|---|---|---|---|---|---|---|
| ៛/ដុល្លារ | ៤០៦៥៛/១$ | ៤០០០៛/១$ | ៤០៦៥៛/១$ | បាត/ដុល្លារ | ៣០,១បាត/១$ | ២៩,២៦បាត/១$ | ៣១,៨៧បាត/១$ |
| ៛/បាត | ១៣៥៛/១បាត | ១៣៧៛/១បាត | ១២៧៛/១បាត | ដុង/ដុល្លារ | ២០៩៨០ដុង/១$ | ២០៩០៥ដុង/១$ | ២០៨៦០ដុង/១$ |
| ៛/ដុង | ០,១៩៤៛/១ដុង | ០,១៩២៛/១ដុង | ០,១៩៥៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែឧសភា ឆ្នាំ ២០១៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១.ចំណូលថវិកាជាតិ៖** អនុវត្តបាន ៨៦១,៧ ពាន់លានរៀល (មធ្យមប្រចាំខែ៧២% នៃគម្រោង) ក្នុងនោះ ចំណូលចរន្ត ៦៦៥,២ ពាន់លានរៀល (មធ្យមប្រចាំខែ ៩៥% នៃគម្រោង) និងចំណូលមូលធន ១៩៦,៥ ពាន់លានរៀល។

➢បើធៀបនឹងខែមុនចំណូលថវិកាជាតិ ថយចុះ៤,៥% ប៉ុន្តែកើនឡើង ៣៩,១% *ធៀបនឹងខែដូចគ្នាឆ្នាំមុន។* ក្នុងនោះ ចំណូលចរន្តថយចុះ ២៥,៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៧,៣% *ធៀបនឹងខែដូចគ្នាឆ្នាំមុន។*

ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ — ២០១៣ (ពាន់លានរៀល)



➢នៅក្នុងចំណូលចរន្តៈ

✓ចំណូលសារពើពន្ធមានចំនួន ៦០២,៨ ពាន់លានរៀល ថយចុះ ២៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៦២,៤ ពាន់លានរៀល ថយចុះ ១៩,៦% ធៀបនឹងខែមុន និងថយចុះ ២៥,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចកៈបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចកៈបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +៨,៩% | (+១៤,៦%) | ➢ នេសាទ: +៥,៧% | (-៣៥,៨%) |
| ➢ ចំណូលពន្ធដារ: -៤៧,៦% | (+៤,២%) | ➢រុក្ខាប្រមាញ់ : :+១០៤% | (+១៦៤%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: -២៣,៧% | (+១៦,៥%) | ➢ អាកាសចរណ៍ស៊ីវិល: -៥៧% | (-៩៦%) |
| ✧ កាស៊ីណូ : -៤៨% | (-១២,៧%) | ➢ ផលទុនទេសចរណ៍: -៦% | (-៣១%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +៤៨៦,២% | (-៥៤,៤%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: -៧៧% | (-៧៦%) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : -២,៧% | (+៤៩%) | ➢អាករស្ពានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): -២៥% | (-១៤%) |

២.២. *ចំណាយថវិកាជាតិ៖* អនុវត្តបានចំនួន ៧២១ ពាន់លានរៀល( *មធ្យមប្រចាំខែ ៥០% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៦១០ ពាន់លានរៀល ( *មធ្យមប្រចាំខែ ៧១% នៃគម្រោង*) និង**ចំណាយមូលធន** ចំនួន ១១២ ពាន់លានរៀល។

➢*បើធៀបនឹងខែមុន*ចំណាយថវិកាជាតិ កើនឡើង ៣% និង កើនឡើង ១១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្ត ថយចុះ ២% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯចំណាយមូលធន កើនឡើង ៣៥% ធៀបនឹងខែមុន និងកើនឡើង ១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢*ថវិកាជាតិនៃខែឧសភាមានអតិរេក ១៤០ ពាន់លានរៀលស្មើនឹង ៣៥ លានដុល្លារ ស.រ.អា។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែឧសភា ឆ្នាំ២០១៣ មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ $M_2$ មានចំនួន ៣១៧០៩ ពាន់លានរៀល កើនឡើង ១,៧% ធៀបនឹងខែមុន និងកើនឡើង ២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ កំណើន $M_2$ ធៀបនឹងខែមុន បណ្តាលមកពីប្រាក់បញ្ញើចរន្តកើនឡើង ៧,៣% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ កើនឡើង ៧% និង ប្រាក់បញ្ញើជារូបិយបណ្ណកើនឡើង ២,៣%។

➢ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៦,៩% នៃរូបិយវត្ថុ $M_2$ និង ប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,១%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុខែឧសភា ឆ្នាំ២០១៣



| សមាមាត្រចំនួនប្រាក់រៀល ក្នុងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុ | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ១៧,២% | ១៧,៣% | ១៧,០% | ១៧,៣% | ១៦,៩% | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៧% | ១៣,៧% | ១៣,៩% | ១៤,០% | ១៣,៣% | | | | | | | |

បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែឧសភា២០១៣: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ (ខែមេសា និងឧសភា : មិនទាន់មានតួលេខ)

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១០២៧៥ ពាន់លានរៀលកើនឡើង ១,២% ធៀបនឹងខែមុន និងកើនឡើង ២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢*ការផ្តល់ឥណទាន៖*

| *ផ្តល់ដោយ* | *ឧសភា ២០១៣* | *មេសា ២០១៣* | *ឧសភា ២០១២* |
|---|---|---|---|
| ធនាគារពាណិជ្ជ(ពាន់លានរៀល) | ២៦១១០ | ២៥៤៣៨ | ២០០០៤ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | មិនទាន់មានតួលេខ | ៤១១៨ | ២៩១៥ |

➢***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែឧសភា៖

| *ប្រភេទអត្រាការប្រាក់* | *ឧសភា២០១៣* | *មេសា២០១៣* | *ឧសភា២០១២* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៥,៩៥% | ៦,០៦% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៨៤% | ១២,៤៨% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៤,៤១% | ៤,៤៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១២,០៧% | ១១,៧៦% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែឧសភា ឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម៖**

✓ផលិតផលនេសាទមាន ៤៣ ពាន់តោន កើនឡើង ១% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៣៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម៖

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា មានចំនួន ៣៣០ GWh កើនឡើង ៣,៩% ធៀបនឹងខែមុន និង កើនឡើង ២៣,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះវារីអគ្គិសនីមានចំនួន ១៤,៧ GWh ថយចុះ ៩,៤% ធៀបនឹងខែមុន និងថយចុះ ២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៦៩ លានដុល្លារ កើនឡើង ២៤% ធៀបនឹងខែមុន និងកើនឡើង ១៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន—ឧសភា ២០១៣ | ចំនួន—មេសា ២០១៣ | ចំនួន—ឧសភា ២០១២ |
|---|---|---|---|
| ▪ រោងចក្រថ្មីដែលបានចុះបញ្ជី | ២៤ | ១២ | ២២ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ៩៨០ | ៩៥៦ | ៧៨១ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៧ | ១៦ | ៦ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១២ | ៨ | ៥ |

➢សំណង់ (ការអនុញ្ញាត)៖

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៤២៤ ពាន់ម² កើនឡើង ២៣៨% ធៀបនឹងខែមុននិងកើនឡើង ៧២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១២៨ លានដុល្លារ កើនឡើង ២៦៧% ធៀបនឹងខែមុន និងកើនឡើង ៧១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម²—ឧសភា ២០១៣ | ពាន់ម²—មេសា២០១៣ | ពាន់ម²—ឧសភា ២០១២ |
|---|---|---|---|
| ▪ លំនៅឋាន | ២៦៩,០ | ៥៥,៨ | ១១០,១ |
| ▪ ឧស្សាហកម្ម | ៦៣,០ | ៤១,៣ | ១១២,៦ |
| ▪ ពាណិជ្ជកម្ម | ៨០,៨ | ៦,១ | ៦,៣ |
| ... | | | |
| អនុញ្ញាតសរុប | ៤២៤ | ១២៦ | ២៤៦ |

✓ ដូច្នេះសំណង់ដែលពេញនិយមនាខែនេះគឺលំនៅឋាន ៦៣% នៃផ្ទៃក្រឡាអនុញ្ញាតសរុប ពាណិជ្ជកម្ម ១៩% និងឧស្សាហកម្ម ១៥% ។

➢ការងារ៖

| ប្រភេទ | នាក់ : ឧសភា២០១៣ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១០៦២ | -៣៥% | -៦៨% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២០៤៦ | -១០% | -៤៦% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១១៣៨ | +៣៩% | +៧៧% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៩០៨ | -៣៧% | -៧១% |

**➢វិនិយោគ៖**

✓គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)៖

| ប្រភេទ | ឧសភា២០១៣ | មេសា២០១៣ | ឧសភា២០១២ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៧៣ | ២១៤ | ១៧៩ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៥៧ | 0 | 0 |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១៦ (0) | ១០៨ (១០) | ១៧៩ (៥៥) |
| វិស័យទេសចរណ៍ | 0 | ១០៦ | 0 |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | 0 | 0 | 0 |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៧ | ១២ | ២៣ |
| បង្កើតការងារ (ពាន់នាក់) | ៤ | ៨ | ៣១ |

**➢សេវាកម្ម និងទេសចរណ៍៖**

**✓ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន – ឧសភា២០១៣ | ចំនួន–មេសា២០១៣ | ចំនួន–ឧសភា២០១២ |
|---|---|---|---|
| ▪ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៥០ | ២២៨ | ២៤៦ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២ | 0 | ២ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ? | ១១៦ | ២៣១ |

✓**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៥៤៥ ពាន់តោន កើនឡើង ៨% ធៀបនឹងខែមុន និង កើនឡើង ២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: -២១% | (-១៦%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +៨៨% | (+៨០%) |
| ▪ កំពង់ផែកំពង់សោម: -១% | (+៣៤%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៧២% | (+៦៤%) |

**➢ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៥ | -៣៥% | +៨% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៣ | -១៦% | -១១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣២ | -៩១% | -៨៨% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ២៩២ | +២៥៦% | +៣៥៧% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ២៨៨ | -១២% | +២៣% |
| ✓ តាមផ្លូវអាកាស | ១២៦ | -១៣% | +២១% |
| ✓ តាមផ្លូវគោក និងទឹក | ១៦១ | -១១% | +២៥% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលខែឧសភាមានចំនួន ៣១៨៣ពាន់លានរៀល (៧៩៥,៧លានដុល្លារ) កើនឡើង២១% ធៀបនឹងខែមុន និងកើនឡើង២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

| ទំនិញ | %△ធៀបនឹងខែមុន | %△ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %△ធៀបនឹងខែមុន | %△ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -៤% | +៦% | រថយន្តសរុប (រ.ល.ព) | -១% | +១% |
| ប្រេងម៉ាស៊ូត | +៣% | +១% | រថយន្តសរុប (គ្រឿង) | -៣% | -៥% |
| ឧស្ម័ន | +៥៦% | +៧៨៤% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +២២% | +១៥៧% |
| អគ្គិសនីនាំចូល | -២% | +៣១% | ម៉ូតូ (គ្រឿង) | +១៤% | +៣% |
| ដែកសំណង់ | -៣៩% | -៨៧% | អង្ករ | -៣៨% | +៣០៩៤% |
| ស៊ីម៉ង់ត៍ | +៣១% | +១១% | ផ្លែឈើនិងបន្លែ | -៤% | -៥២% |
| គ្រឿងអេឡិចត្រូនិក | -៣៦% | ៤២%- | ជីនិងថ្នាំកសិកម្ម | +១០៣% | +៣១% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៧% | -២៥% |

➡ **ការនាំចេញ**ខែឧសភាឆ្នាំ២០១៣ មានចំនួន ២២៦៧ ពាន់លានរៀល ស្មើនឹង ៥៦៦,៨ លានដុល្លារ ស .អា.រ. នៃការ ៧១%)នាំចូល( កើនឡើង ៣៤% ធៀបនឹងខែមុន និងកើនឡើង ៣៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %△ធៀបនឹងខែមុន | %△ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %△ធៀបនឹងខែមុន | %△ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១៧០១% | +២៤៧២% | ផលិតផលនេសាទ | +៤១% | +៤១៧% |
| វាយនភណ្ឌនិងស្បែកជើង | +៣៩% | +២២% | កៅស៊ូ | +១៤៣% | +៤៧% |
| អង្ករ | +២៣% | +១៤៩% | | | |

➡ក្នុងខែឧសភានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៩១៥ ពាន់លានរៀល ស្មើនឹង ២២៩ លានដុល្លារ ស.អា.រ.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែឧសភា ឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| លរ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលអាកាសចរណ៍ស៊ីវិល | -៥៧% | -៩៦% | ជាប្រភេទចំណូលមិនមែនសារពើពន្ធ |
| ២ | ផលទុននៃសកម្មភាពទេសចរណ៍ | -៦% | -៣១% | ជាប្រភេទចំណូលមិនមែនសារពើពន្ធ |
| ៣ | ចំណូលប្រៃសណីយ៍ និងទូរគមនាគមន៍ | -៧៧% | -៧៦% | ជាប្រភេទចំណូលមិនមែនសារពើពន្ធ |
| ៤ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. | -៦៦% | -៥៩% | — |
| ៥ | ចំនួនទេសចរកម្ពុជាចេញក្រៅប្រទេស | +២៥៦% | +៣៥៧% | ចំនួននាខែឧសភាស្មើនឹង ២៩២ ពាន់នាក់ |
| ៦ | ចំនួនទេសចរមកព្រះរាជាណាចក្រកម្ពុជា | -១២% | +២៣% | ចំនួននាខែឧសភាស្មើនឹង ២៨៨ ពាន់នាក់ |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១) សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងអំលុងពេល៥ខែដើមឆ្នាំនេះ មានការវិវត្តក្នុងកម្រិតមួយទាប បើធៀបនឹងទិសដៅអតិផរណា ៥% នៃគោលនយោបាយប្រចាំឆ្នាំ។ មូលហេតុសំខាន់នៃការវិវត្តន៍សន្ទស្សន៍ថ្លៃគឺក្រុមម្ហូបអាហារ ដែលក្នុងនោះគួរកត់សម្គាល់ សាច់គោ បន្លែ និងផ្លែឈើ។



២) កម្រិតដុល្លារូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជា មាននិន្នាការកើនឡើង។

៣) យោងតាមតួលេខនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទុនវិនិយោគបរទេសដែលអនុញ្ញាតមានការថយចុះគួរឲ្យចាប់អារម្មណ៍។ ក្នុងរយៈពេល ៥ខែ ដើមឆ្នាំ២០១៣ ការអនុញ្ញាតទុនវិនិយោគមានចំនួន ៤៩២ លានដុល្លារ ស.រ.អា រីឯ ក្នុងរយៈពេលដូចគ្នា ឆ្នាំ២០១២ សូចនាករនេះមានចំនួន ១២២៨ លានដុល្លារ ស.រ.អា។

៤) មានការកើនឡើងយ៉ាងគំហុក នៃចំនួនទេសចរជាតិចេញទៅក្រៅប្រទេសក្នុងខែឧសភា ឆ្នាំ២០១៣ នេះ ដែលលើសចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជាទៅទៀត។ ដូចនេះកម្ពុជាទំនងជាមានឱនភាពជញ្ជីងសេវា ទេសចរណ៍ ក្នុងខែឧសភានេះ។

*សេចក្តីសន្និដ្ឋាន៖*

ដើម្បីស្ថេរភាពអត្រាប្តូរប្រាក់ សេដ្ឋកិច្ចកម្ពុជាមាននិន្នាការកើនឡើងនៃដុល្លារូបនីយកម្ម ។ យើងមានការរំពឹងទុកថាយន្តការតម្រង់ទិសអត្រាប្តូរប្រាក់នេះ នឹងធ្វើឲ្យសម្រេចបាននូវទិសដៅស្ថេរភាពថ្លៃ (ផែនការអតិផរណា៥% ប្រចាំឆ្នាំ )។ លទ្ធផលឆ្នាំកន្លងមកថ្មីៗនេះបង្ហាញថា អត្រាអតិផរណាដែលអនុវត្តបានពិតជាមានកម្រិតទាប (ឬមួយក្រោម ឬមួយលើសផែនការ)។ យ៉ាណាក្តី គោលនយោបាយរូបិយវត្ថុបច្ចុប្បន្ន មានដែនកំណត់មួយចំនួនដូចជា៖

ក) ការប្រើប្រាស់ប្រាក់រៀលមានកម្រិតទាប ក្នុងនោះរាប់ទាំងកម្ចី និងបញ្ញើជារៀល ដែលសំខាន់សម្រាប់តំបន់ជនបទ

ខ) ធនាគាជាតិ មិនដើរតួជាអ្នកផ្គត់ផ្គង់សាច់ប្រាក់ (ទុនបម្រុង) ដល់ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ) ការខាតបង់ចំណូលពីការបោះពុម្ពប្រាក់រៀល (Seignorage)

ឃ) មិនអាចប្រើយន្តការរូបិយវត្ថុ ក្នុងការគ្រប់គ្រងអត្រាការប្រាក់។ នាពេលបច្ចុប្បន្នអត្រាការប្រាក់ត្រូវបានកំណត់ដោយយន្តការប្រកួតប្រជែង និងតម្រូវការលើសាច់ប្រាក់។

គួរពង្រីកការប្រើប្រាស់ប្រាក់រៀល និងអនុវត្តកម្មវិធីបដិដុល្លារូបនីយកម្ម ដែលមានចែងក្នុងគោលនយោបាយរូបិយវត្ថុ។

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៦/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីមីទ្ទិញអបអរសាទរខួបលើកទី៦៤ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសាលមហោស្រពនៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ២ | ០៤/០៦/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការរោង ចក្រប្រព្រឹត្តកម្មផលិតទឹកស្អាត និរោធដំណាក់ទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ |
| ៣ | ០៥/០៦/១៣<br>ម៉ោង ០៨:៣០នាទី | ជាអធិបតីភាព ក្នុងសិក្ខាសាលាផ្សព្វផ្សាយដល់ក្រសួង-ស្ថាប័ន ស្តីអំពីការយល់ដឹងលើគម្រោង RIA និងវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារឡឺរ៉ូយ៉ាល់។ |
| ៤ | ០៦/០៦/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធ Studio ថតខ្សែភាពយន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីរួមខេត្តកំពង់ស្ពឺ។ |
| ៥ | ០៦/០៦/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការវាយតម្លៃសេវាសា ធារណៈ។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១០/០៦/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានជួសជុលឡើងវិញនូវកំណាត់ផ្លូវជាតិលេខ២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៧ | ១៣/០៦/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធទីស្នាក់ការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅអគារលេខ១ ផ្លូវសាធារណរដ្ឋប៉ូឡូញ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម ឃឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ១៣/០៦/១៣ ម៉ោង ០៧:៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធទីស្នាក់ការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅអគារលេខ១ ផ្លូវសាធារណរដ្ឋប៉ូឡូញ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។ |
| ៨ | ១៤/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវា សាធារណៈ។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | ១៥/០៦/១៣ ម៉ោង ០៨:៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងឃុំ ត្រពាំងក្រញ៉ូង ស្រុកត្រាំកក់ ខេត្តតាកែវ នៅសាលាបឋមសិក្សាព្រៃក្តួច ភូមិព្រៃក្តួច ឃុំត្រពាំងក្រញ៉ូង ស្រុកត្រាំកក់ ខេត្តតាកែវ។ |
| ១០ | ១៦/០៦/១៣ ម៉ោង ១៧:១៥នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសម័យប្រជុំពេញអង្គលើកទី៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | ១៨/០៦/១៣ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលនិងសាលាកីឡាបាល់ទាត់ជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិថ្នល់ទក្សិណ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។ |
| ១២ | ១៩/០៦/១៣ ពេញមួយថ្ងៃ | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួល និងសហការជាមួយភាគីចិនលើគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៣ | ២០/០៦/១៣ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបលើកទី៦ នៃទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៤ | ២០/០៦/១៣ ម៉ោង ១៥:៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៥ | ២១/០៦/១៣ ពេញមួយថ្ងៃ | បន្តដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួល និងសហការជាមួយភាគីចិន លើគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២២/០៦/១៣ ម៉ោង ០៨:៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារសិក្សាក្នុងវិទ្យាល័យ សុខ អាន សំរោង នៅឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ។ |
| ១៧ | ២៣/០៦/១៣ ម៉ោង ០៨:៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីសម្ពោធកាត់ខ្សែបូរ ឆ្លងសមិទ្ធផលនានា នៅវត្តបានយ ភូមិបានយ ឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១៨ | ២៥/០៦/១៣ ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យនៅជាប់របងជុំវិញបរិវេណ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/០៦/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារ និងពុទ្ធាភិសេក នៅវត្តជួស ឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តជួស ឃុំជីខ្មា ស្រុកទ្រាំងខេត្តតាកែវ។ |
| ២ | ០៦/០៦/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធ Studio ថតខ្សែភាពយន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីរួមខេត្តកំពង់ស្ពឺ។ |
| ៣ | ០៩/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធឆ្លងបណ្ណាល័យសាលារៀន និងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តគីរីជុំដោម ភូមិដោម ឃុំតាអូ ស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៤ | ១០/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានជួសជុលឡើងវិញនូវកំណាត់ផ្លូវជាតិលេខ២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៥ | ១៤/០៦/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរអប្សរា និងមជ្ឈមណ្ឌលអន្តរជាតិខាងបច្ចេកវិទ្យាអវកាស សម្រាប់បេតិកភណ្ឌវប្បធម៌ និងធម្មជាតិ ក្រោមអាណាព្យាបាលនៃអង្គការយូណេស្កូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ២៧/០៦/១៣ ម៉ោង ១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរអប្សរា និងសាជីវកម្មវិស្វកម្មសំណង់ស៊ីវិល នៃសាធារណរដ្ឋប្រជាមានិតចិនស្តីពី" គម្រោងគ្រប់គ្រងប្រកបដោយចីរភាពនូវធនធានដែលមានស្រាប់ សម្រាប់ការអភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាពនៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ និងតំបន់សៀមរាប " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលប្រជុំអង្គនៃទីស្នាក់ការអាជ្ញាធរអប្សរា ខេត្តសៀមរាប។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៣

## ឯកឧត្តម ឌុយ ឆៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/០៦/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារ និងពុទ្ធាពិសេក នៅវត្តជួស ឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តជួស ឃុំជីខ្មា ស្រុកទ្រាំងខេត្តតាកែវ។ |
| ២ | ០៦/០៦/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធ Studio ថតខ្សែភាពយន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីរួមខេត្តកំពង់ស្ពឺ។ |
| ៣ | ០៩/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធឆ្លងបណ្ណាល័យសាលារៀន និងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តគីរីជុំដោម ភូមិដោម ឃុំតាអូ ស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៤ | ១០/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានជួសជុលឡើងវិញនូវកំណាត់ផ្លូវជាតិលេខ២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៥ | ១២/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចែកបណ្ណកម្មសិទ្ធិ ជូនប្រជាពលរដ្ឋក្នុងឃុំលាយបូរ ឃុំអង្គតាសោម និងឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ |
| ៦ | ១៤/០៦/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរអប្សរា និងមជ្ឈមណ្ឌលអន្តរជាតិខាងបច្ចេកវិទ្យាអវកាស សម្រាប់បេតិកភណ្ឌវប្បធម៌ និងធម្មជាតិ ក្រោមអាណាព្យាបាលនៃអង្គការយូណេស្កូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៣

## ឯកឧត្តម ម៉ាន់ ភិរុណ អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/០៦/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារ និងពុទ្ធាភិសេក នៅវត្តជួស ឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តជួស ឃុំជីខ្មា ស្រុកទ្រាំងខេត្តតាកែវ។ |
| ២ | ០៦/០៦/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធ Studio ថតខ្សែភាពយន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីរួមខេត្តកំពង់ស្ពឺ។ |
| ៣ | ០៩/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធឆ្លងបណ្ណាល័យសាលារៀន និងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តគីរីជុំដោម ភូមិដោម ឃុំតាអូ ស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៤ | ១០/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានជួសជុលឡើងវិញនូវកំណាត់ផ្លូវជាតិលេខ២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៥ | ១២/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចែកបណ្ណកម្មសិទ្ធិ ជូនប្រជាពលរដ្ឋក្នុងឃុំលាយបូរ ឃុំអង្គតាសោម និងឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ |
| ៦ | ១៤/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្ដីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>២-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ៧ | ១៤/០៦/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរអប្សរា និងមជ្ឈមណ្ឌលអន្តរជាតិខាងបច្ចេកវិទ្យាអវកាស សម្រាប់បេតិកភណ្ឌវប្បធម៌ និងធម្មជាតិ ក្រោមអាណាព្យាបាលនៃអង្គការយូណេស្កូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១០/០៦/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរអប្សរា និងសាជីវកម្មវិស្វកម្មសំណង់ស៊ីវិល នៃសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីគម្រោងគ្រប់គ្រងប្រកបដោយចីរភាពនូវធនធានដែលមានស្រាប់ សម្រាប់ការអភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាពនៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ និងតំបន់សៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសាលប្រជុំអង្គនៃទីស្នាក់ការអាជ្ញាធរអប្សរា ខេត្តសៀមរាប។ |

# ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារសិក្សាក្នុងវិទ្យាល័យ សុខ អាន សំរោង នៅឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ

កាលពីព្រឹកថ្ងៃសៅរ៍ ទី២២ ខែមិថុនា ឆ្នាំ២០១៣ កាលពីថ្ងៃពុធទី៥ ខែមិថុនា ឆ្នាំ២០១៣ នៅឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានអញ្ជើញបញ្ចុះបឋមសិលាសាងសង់អគារសិក្សាមួយខ្នងពីរជាន់ មាន ១០បន្ទប់ ក្នុងវិទ្យាល័យ សុខ អាន សំរោង ដែលស្ថិតនៅឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ជាអំណោយរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង លោកជំទាវ។





លោក **ញ៉ែម ស្រស់** អភិបាលនៃគណៈអភិបាលស្រុកសំរោង ខេត្តតាកែវ បានបញ្ជាក់ថា ឆ្នាំសិក្សា២០១២-២០១៣ នៅស្រុកសំរោង ខេត្តតាកែវ មានវិទ្យាល័យចំនួន ០៩ អនុវិទ្យាល័យចំនួន ០៦ សាលាបឋមសិក្សា ចំនួន ៤៦ ។ សាលាមត្តេយសិក្សារបស់រដ្ឋចំនួន ២២ថ្នាក់ និងសាលាមតេយ្យរបស់សហគមន៍ចំនួន ២៧ថ្នាក់។ លោកគ្រូ-អ្នកគ្រូ ទាំងវិទ្យាល័យ និងអនុវិទ្យាល័យ ចំនួន ៤៨៣នាក់ ។ សិស្សវិទ្យាល័យចំនួន ៩.៤៩៣ នាក់។ សិស្សអនុវិទ្យា ល័យចំនួន ១.៧២០ នាក់ ។ លោកគ្រូ-អ្នកគ្រូ ទាំងសាលាបឋមសិក្សា ទាំងសាលាមតេយ្យរបស់រដ្ឋ និងសាលាមត្តេយរបស់សហគមន៍មានចំនួន ៥២៦នាក់ ។ សិស្សសាលាបឋមសិក្សាមានចំនួន ១៩០.៤៥៩នាក់ សិស្សសាលាមតេយ្យរបស់រដ្ឋ មានចំនួន ១.៣១៤ នាក់ និងសិស្សសាលាមតេយ្យរបស់សហគមន៍មានចំនួន ១.១១០នាក់ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** បានមានប្រសាសន៍ថា ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ វិស័យអប់រំត្រូវបានស្តារ និងកសាងឡើងវិញជាបន្ទាន់ តាមរយៈការបង្កើតឲ្យមានសាលារៀន ដោយផ្តើមចេញពីអ្នកចេះច្រើន បង្រៀនអ្នកចេះតិច ហើយអ្នកចេះតិច បង្រៀនអ្នកមិនចេះសោះ។ ព្រមជាមួយនោះ យុទ្ធនាការបំបាត់អក្ខរកម្ម ត្រូវធ្វើឡើងតាមគ្រប់រូបភាពនៅទូទាំងប្រទេស ដើម្បីកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បន្ថែមទៀតថា ចក្ខុវិស័យដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា ក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេស គឺផ្លូវ ទឹក អគ្គិសនី និងធនធានមនុស្ស។ ហេតុដូច្នេះហើយ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកវិស័យអប់រំ បណ្តុះបណ្តាលធនធានមនុស្ស ជាវិស័យអាទិភាពមួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ រយៈពេលជាង ៣០ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជា បានជំនះរាល់ការលំបាកក្នុងការស្តារ កសាង ពង្រឹង និងពង្រីកវិស័យអប់រំ ឲ្យទទួលបានជោគជ័យ និងមានការរីកចម្រើនគួរជាទីមោទនៈ។





ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** បានបញ្ជាក់ទៀតថា អគារសិក្សាមួយខ្នងពីរជាន់ ១០បន្ទប់ ដែលជាសមិទ្ធផលថ្មីនេះ នឹងរួមចំណែកដល់ការលើកកម្ពស់វិស័យអប់រំ ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ លើសពីនេះទៀត សមិទ្ធផលថ្មីនេះ ក៏នឹងរួមចំណែកនៅក្នុងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចឲ្យបាននូវគោលដៅទី២ នៃគោលដៅអភិវឌ្ឍសហស្សវត្សន៍កម្ពុជា ពោលគឺ "សម្រេចឲ្យបានជាទូទៅការអប់រំមូលដ្ឋាន រយៈពេល ៩ឆ្នាំ ក៏ដូចជាផែនការអប់រំ សម្រាប់ទាំងអស់គ្នា "។

ក្នុងឱកាសនោះ គណៈអធិបតី បានប្រគេនព្រះសង្ឃ៧អង្គ ក្នុងមួយអង្គៗថវិកា ២០ម៉ឺនរៀល យាយជីតាជី ១០០នាក់ ក្នុងម្នាក់ៗក្រណាត់សមួយដុំ និងថវិកា ១ម៉ឺនរៀល។ លោកគ្រូ-អ្នកគ្រូ ៤១នាក់ ម្នាក់ៗ ៣ម៉ឺនរៀល សិស្សវិទ្យាល័យ ៤០០នាក់ ក្នុងម្នាក់ៗថវិកា ៥ពាន់រៀល សៀវភៅ២ក្បាល ប៊ិចមួយដើម។ ក្រុមយុវជនកាយរិទ្ធិ ៥០នាក់ និងក្រុមយុវជនកាកបាទក្រហម ៥០នាក់ ក្នុងម្នាក់ៗ ១ម៉ឺនរៀល ។ វិទ្យាល័យ សុខ អាន សំរោង ១លានរៀល សាលាស្រុកសំរោង ១លានរៀល និងចំណាយផ្សេងៗចំនួន ១លានរៀលទៀត ។ សរុបរួមថវិកា ៩.៦៣០.០០០រៀល សៀវភៅ ៨០០ក្បាល ប៊ិច ៤០០ដើម និងក្រណាត់ស ១០០ដុំ។

ជាទីបញ្ចប់គណៈអធិបតី និងអ្នករួមដំណើរបានប្រារព្ធពិធីបញ្ចុះបឋមសិលា សាងសង់អគារសិក្សា ១ខ្នង ពីរជាន់ ១០បន្ទប់ ៕

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡៃន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ច៉ាន់ តិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង រត្នមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ធារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត ភក្កដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in